# អត្ថបទ ធម៌ទេសនា

# ស្តីអំពី

# “រូបកាយ”

ភិក្ខុ **កែវ-អ៊ុន ឬ សំអឿន**

“ **អភិញ្ញានសីលោ**”

វត្ត **សម្តេចព្រះមហាឃោសានន្ទ**

“សាខាមជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរអន្តរជាតិ”

ទីក្រុងអូកឡិនដ៍ រដ្ឋកាលីហ្វ័រនីញា

សហរដ្ឋ អាមេរិក

ព្រហស្បតិ៍១៥កើតចេត្រ,ម្សាញ់បញ្ចស័កព.ស.២៥៥៦;២០មេសាគ.ស.២០១៣

សូមលោកអ្នក មេត្តានឹកឈ្មោះខ្ញុំ,ហើយឧទ្ទិសកុសលឲ្យដល់ខ្ញុំផង!

## អត្ថបទ ស្ដីអំពី **“រូបកាយ”**

និយាយអំពីរូបកាយនេះ មិនមែននិយាយត្រឹមតែរូបកាយរបស់យើងទាំងអស់គ្នានៅទីនេះប៉ុណ្ណោះទេ! គឺនិយាយអំពីរូបកាយរបស់មនុស្សទូទៅនៅលើពិភពលោកនេះទាំងមូលតែម្ដង មិនថាជាតិណាសាសន៍ណា នគរណាឬទ្វីបណាឡើយ។ រូបកាយរបស់មនុស្សយើងទាំងអស់គ្នានេះ បើតាមទស្សនៈរបស់ពាហិរសាសនាគឺសាសនាដទៃក្រៅពីព្រះពុទ្ធសាសនាមានសាសនាព្រាហ្មណ៍សាសនាគ្រីស្ដជាដើម គេនិយាយថារូបកាយរបស់មនុស្សទាំងអស់ទូទៅនៅលើពិភពលោកនេះគឺព្រះព្រហ្ម ឬព្រះអាទិទេព, ព្រះជាម្ចាស់របស់គេ ជាអ្នក“បង្កើត” ថាព្រះរបស់គេហ្នុងចេះបង្កើតទាំងអ្វីៗគ្រប់យ៉ាងទាំងអស់ផង,ប៉ុន្តែគេមិនបាននិយាយថាព្រះរបស់គេហ្នុង!នរណាជាអ្នកបង្កើតនោះផងទេ, ប្រហែលជាគេភ្លេចក៏មិនដឹង ហើយគេថានៅក្នុងខ្លួនរបស់មនុស្សគ្រប់គ្នាមានព្រលឹងឬវិញ្ញាណជាធាតុទៀងមិនចេះរលាយរលត់ទៅណាទេ, គេថារូបកាយរមែងបែកធ្លាយរលត់រលាយស្លាប់ទៅជាធម្មតាតែព្រលឹងមិនចេះស្លាប់ទេ! គេថារូបកាយប្រៀបដូចជា“ផ្ទះ” ឯព្រលឹងប្រៀបដូចជា“ម្ចាស់ផ្ទះ”។គេថាបើកាលណាផ្ទះចាស់ត្រូវភ្លើងឆេះឬវិនាសដោយហេតុអ្វីមួយម្ចាស់ផ្ទះត្រូវចុះចេញពីផ្ទះចាស់ហើយដើរស្វែងរកផ្ទះថ្មីនៅអាស្រ័យតទៅទៀតទៅ!។ នែ! ពាហិរសាសនាគេនិយាយអញ្ចឹង,គេនិយាយបែបធូរល្ហុយអញ្ចឹង! រឿងនេះ បើយើងធ្វើការពិចារណាបន្តិចទៅតាមទស្សនៈរបស់ពួកគេនេះ! យើងឃើញថាព្រះជាម្ចាស់របស់គេហ្នុងមិនមាន“យុត្តិធម៌”ទេ! ពីព្រោះថាប្រសិនបើព្រះជាម្ចាស់របស់គេនោះជាអ្នក“ពូកែ”ចេះបង្កើតអ្វីៗអញ្ចឹងហើយ,ម៉េចក៏មិនបង្កើតមនុស្សមកឲ្យជាអ្នកមានទ្រព្យសម្បត្តិច្រើនៗទាំងអស់គ្នាទៅ?ម៉េចមិនបង្កើតមនុស្សឲ្យល្អទាំងអស់គ្នាទៅ? ម៉េចក៏បង្កើតគ្នាមកហើយឲ្យគ្នាក្រ!ឲ្យគ្នាអាក្រក់? ជួនកាលបង្កើតគ្នាឲ្យខ្វាក់ភ្នែក,បង្កើតឲ្យគ្នាគ,ថ្លង់,តាំងពី

កំណើតមកតែម្តង!ឲ្យគ្នាលំបាកវេទនាយ៉ាងក្រៃលែង។នែ!ហ្នឹងហើយដែលថាព្រះជាម្ចាស់របស់ពួកគេហ្នុងមិនមាន“យុត្តិធម៌”នោះ!ពីព្រោះបង្កើតមនុស្សមកមិនឲ្យដូចគ្នា!។ នេះយើងគ្រាន់តែ ធ្វើការពិចារណាទៅតាមទស្សនៈរបស់ពួកគេតែបន្តិចប៉ុណ្ណោះ,មិនមែនជាការចូលទៅជ្រៀតជ្រែកក្នុងជំនឿរបស់ពួកគេទេ,សូមអស់លោកអ្នកស្តាប់យល់ឲ្យច្បាស់អញ្ចឹង,ចំណែកឯព្រះពុទ្ធសាសនាមិននិយាយដូច្នោះទេ,ព្រះពុទ្ធសាសនានិយាយតែអំពីកម្ម-ផល,និងនិយាយតែពីរឿងខន្ធ៥ទៅវិញ,គឺរូបក្ខ័ន្ធ,វេទនាខ័ន្ធ,សញ្ញាខន្ធ័,សង្ខារខ័ន្ធនិងវិញ្ញាណក្ខ័ន្ធហើយដែលខ័ន្ធទាំង៥នេះព្រះពុទ្ធទ្រង់រកឃើញ(ត្រាស់ដឹងដោយព្រះបញ្ញាញាណរបស់ព្រះអង្គផ្ទាល់!ថាជារបស់មិនទៀង,មិនស្ថិតស្ថេរ,មិននឹងន មានការប្រែប្រួលឥតឈប់កើតរលត់ៗជានិច្ច ឯអ្វីៗដែលគេសន្មតថា មនុស្សថាជាសត្វថាខ្លួនគេ,ខ្លួនឯងខ្លួនអញជាដើមនោះ គឺមានតែខន្ធ៥ប៉ុណ្ណឹង!មិនមានអ្វីក្រៅពីហ្នឹងទៀតទេ! ជារបស់ដែលកើតឡើង ដោយការផ្សំធាតុទាំង៤គឺដី,ទឹកភ្លើង, ខ្យល់នោះឯង!។ និយាយតែត្រឹមប៉ុណ្ណឹងចុះ មិននិយាយឲ្យជ្រៅវែងឆ្ងាយទៅទៀតទេ! ព្រោះវាមានពិស្តារនៅក្នុងគម្ពីរព្រះអភិធម្មដ៏ជ្រៅឯណោះហើយ! ។ តទៅនេះ ខ្ញុំនិយាយតាមបែបជាលោកិយធម៌ជាធម៌រាក់ៗ ឲ្យស្រួលស្តាប់និងស្រួលយល់ ហើយក៏មិននិយាយពីរឿងការ“ក”កើតនៃជីវិតរបស់មនុស្សសត្វផងដែរគឺនិយាយត្រឹមតែរូបកាយរបស់មនុស្សតែប៉ុណ្ណោះ។ សាធុសប្បុរសទាំងឡាយ! មនុស្សយើងទាំងអស់គ្នានៅលើដុំពិភពលោកនេះទាំងមូល ដែលអាចរស់នៅបាន ដោយត្រូវអាស្រ័យបច្ច័យទាំងឡាយ៤គ្រប់ៗគ្នា!។ ទី១-ចីវរបច្ច័យ បានដល់ចីពរ,ស្បង់,សង្ឃាដី,សំពត់,ខោអាវ,ជាដើម។ទី២-បិណ្ឌបាតបច្ច័យ បានដល់,បាយទឹក,សំឡ,នំចំណី,ផ្លែឈើ,ផ្សេងៗជាដើម។ ទី៣-សេនាសនបច្ច័យ បានដល់,ព្រះវិហារ,សាលា,ផ្ទះ,ភូមិគ្រឹះគ្រែពូកជាដើម។ទី៤-គិលានបច្ច័យ បានដល់ភេសជ្ជៈគ្រប់មុខមានស្ករ

ស្ករតែទឹកដោះគោ,ប្រេងទឹកឃ្មុំ,និងថ្នាំកែរោគផ្សេងៗជាដើម។ បច្ច័យទាំង៤នេះបើខ្វះណាមួយមនុស្សយើងមិនអាចរស់បានឡើយ,រួចដើម្បីបានបច្ច័យទាំង៤នេះមកប្រើប្រាស់ដើម្បីរស់ព្រះពុទ្ធទ្រង់ចង្អុលបង្ហាញនូវមាគ៌ាដ៏ប្រសើរ៤យ៉ាង ហៅថា ទិដ្ឋធម្មិកត្ថៈ ប្រយោជន៍សម្រាប់ក្នុងបច្ចុប្បន្នគឺៈទី១-ឧដ្ឋានសម្បទា ជាមនុស្សព្រះពុទ្ធទូន្មានថាៈត្រូវខំប្រឹងធ្វើការងារគ្រប់ជំពូកឲ្យអស់ពីសមត្ថភាព,កុំខ្ជិលច្រអូស,កុំស្ពឹកស្រពន់កុំទំរន់, បណ្តោយឲ្យពេលវេលាកន្លងទៅដោយឥតប្រយោជន៍ ធ្វើការដើម្បីបានកម្រៃពីការងារនោះៗមកជាលុយកាក់ក្តីជាវត្ថុអ្វីផ្សេងៗក្តីប្រមូលទុកដាក់ដើម្បីផ្គត់ផ្គង់ជីវភាពហើយក្នុងកិច្ចប្រកបមុខរបរទាំងនោះព្រះពុទ្ធទូន្មានថាត្រូវប្រកាន់ខ្ជាប់ នូវអំពើសុចរិតសច្ចៈយុត្តិធម៌ជានិច្ច!, ទាំងផ្លូវកាយ,វាចា,ចិត្ត,ធ្វើយ៉ាងណាឲ្យបានរបស់មកខ្លួនយើងផងនិងកុំឲ្យប៉ះពាល់ដល់សិទ្ធិឬខូចប្រយោជន៍របស់អ្នកដទៃទាំងពួងផង បើធ្វើបានយ៉ាងនេះទើបប្រសើរ!។ ទី២-អារក្ខសម្បទា ទាំងអស់គ្នារកទ្រព្យសម្បត្តិបានមកហើយ! ទោះតិចឬច្រើនព្រះពុទ្ធទូន្មានថាត្រូវចេះថៃទាំសន្សំសំចៃលៃលកទុកដាក់ឲ្យបានគង់វង់ កុំឲ្យបាត់បង់ទៅវិញ ដោយមិនសមហេតុមិនសមផល! ។ ទី៣-កល្យាណមិត្តតា ទាំងអស់គ្នាត្រូវចេះទំនាក់ទំនងការងារគ្រប់យ៉ាងជាមួយអតិថិជន  ជាកល្យាណមិត្តគឺសេពគប់រាប់រកតែជាមួយមនុស្សណាមានចិត្តស្មោះត្រង់ជាមួយគ្នាទៅវិញទៅមក,ចេះយល់អធ្យាស្រ័យគ្នា,ចេះដឹងជួយទុក្ខធុរៈគ្នា, ជួយផ្តល់យោបល់ល្អៗដល់គ្នានិងគ្នាពោលតែពាក្យមានប្រយោជន៍ទាំងអស់គ្នា ទី៤-សមជីវិតា រកទ្រព្យសម្បត្តិបានមកហើយទោះមានដល់កំរឹតណាក៏ដោយ,ជាមហាសេដ្ឋីក៏ដោយ, ព្រះពុទ្ធទ្រង់ទូន្មានថាត្រូវរៀនរស់នៅយ៉ាងសាមញ្ញឲ្យបាន! កុំប្រកាន់អស្មិមានៈឲ្យសោះកុំប្រកាន់ថា“អញជាអ្នកមានជាងគេ!អញជាអ្នកគ្រាន់បើជាងគេមានតែអញទេ!” ដូច្នេះជាដើម, ត្រូវរស់នៅតាមបែប មនុស្សមានមនុស្សធម៌ដ៏ល្អប្រសើរ! ។

ត្រូវធ្វើខ្លួនឲ្យជាម្ចាស់លើទ្រព្យសម្បត្តិកុំឲ្យទ្រព្យសម្បត្តិធ្វើជាម្ចាស់លើខ្លួនយើងវិញ ព្រោះជាមនុស្សកាលណាឲ្យទ្រព្យសម្បត្តិ ធ្វើជាម្ចាស់វាមានគ្រោះថ្នាក់ធំធេងណាស់!។ រួចនៅលើពិភពលោកទាំងមូលនេះមនុស្ស! ដែលរកទ្រព្យសម្បត្តិបានមកហើយនិងជាអ្នកមានស្តុកស្តម្ភហើយមានបុណ្យសក្តិតូច-ធំតាមសមត្ថភាពហើយ, សួរថាៈ តើ? ជាមនុស្ស!នៅត្រូវការប្រាថ្នាមានអ្វីទៀតទេ?ចម្លើយថាៈមាន!ៗមនុស្ស! មិនចេះគ្រប់គ្រាន់ទេ!ព្រះពុទ្ធពោលថាៈ **នត្ថិ តណ្ហា សមានទី** ស្ទឹង, ឬទន្លេ,មានទឹកហូរខ្ជួលខ្ជាញ់ពោរពេញយ៉ាងណាក៏ដោយ ក៏មិនស្មើនឹងតណ្ហារបស់មនុស្សលោកដែរ!គឺមនុស្សនៅត្រូវការសេចក្តី"សុខ,ទៀតសេចក្តីសុខនេះសំខាន់ណាស់, សំខាន់បំផុត! ហើយសេចក្តីសុខនេះមាន២ប្រភេទគឺសេចក្តីសុខផ្លូវកាយ និងសុខផ្លូវចិត្ត,រួចបណ្ឌិតលោកពោលថាៈសេចក្តីសុខផ្លូវចិត្តប្រសើរជាង!សេចក្តីសុខទាំង២ផ្លូវនេះបើវាមិនបានតែសុខតាមប្រាថ្នាទេ វាក៏អាចក្លាយ ទៅជាទុក្ខវិញដែរ,ព្រោះកន្លែងត្រង់ហ្នឹងសភាវៈ២ហ្នឹងវាផ្លាស់ប្តូរគ្នា។ រីឯរោគឬជម្ងឺក៏មាន២ផ្លូវដូចគ្នាដែររោគតាមផ្លូវកាយនិងរោគតាមផ្លូវចិត្ត។ព្រះពុទ្ធសាសនាបានបង្រៀនមនុស្សឲ្យមានអនាម័យ ដើម្បីការពារកុំឲ្យមានរោគ គឺការពារមុនប្រសើរជាងមានរោគហើយទើបព្យាបាលជាក្រោយដោយមានព្រះពុទ្ធដីកាបញ្ជាក់ថា"អរោគ្យ បរមាលាភា"ប្រែៈការមិនមានរោគជាលាភដ៏ក្រៃលែង!គឺមនុស្សយើងដែលមានរូបល្អគ្រប់គ្នានេះ មិនចាំបាច់បានរបស់អ្វីទេ!គឺគ្រាន់តែមានរូបហើយមិនមានរោគនោះ ព្រះពុទ្ធពោលថាគឺវាជាលាភដ៏ធំក្រៃលែងណាស់ទៅហើយ! ហើយព្រះពុទ្ធសាសនាក៏ទទួលស្គាល់តាមផ្លូវវេជ្ជសាស្ត្រដែរ! ថាជម្ងឺវាបណ្តាលមកពីមេរោគឬខូចផ្នែកណាមួយនៃអាការៈ ក្នុងខ្លួនមនុស្ស, ឯថ្នាំក៏អាចដាក់ព្យាបាលឲ្យជាបានដែរ ប្រសិនបើថ្នាំនោះវាស្របទៅតាមប្រភេទនៃជម្ងឺនោះៗ ប៉ុន្តែបានតែជម្ងឺតាមផ្លូវកាយទេ! ឯជម្ងឺតាមផ្លូវចិត្តឥតបានសោះឡើយ

ជម្ងឺតាមផ្លូវចិត្តមានតែព្រះធម៌ទេ!ទើបអាចដោះស្រាយបាន។ ព្រះពុទ្ធទ្រង់ទូន្មានមនុស្សឲ្យដោះស្រាយបញ្ហាទាំងឡាយទៅតាមហេតុ-ផលរបស់វា!បើហេតុដែលនាំឲ្យមានជម្ងឺនោះយ៉ាងណា? ត្រូវដោះស្រាយទៅតាមហេតុនោះៗ,បើដោះស្រាយហេតុនោះៗបានហើយជម្ងឺនោះៗក៏វាស្ងប់រម្ងាប់ជាសះស្បើយទៅដែរ! ព្រោះជម្ងឺវាជាផល, ប្រសិនបើគេទាំងឡាយដោះស្រាយហេតុនោះៗឲ្យរលត់បានហើយឯផលនោះក៏វាត្រូវតែរលត់ទៅដែរ។ ប៉ុន្តែមានមនុស្សមួយចំនួនខ្លះបើគេមានរូបកាយស្អាតល្អទឹកមុខស្រស់ប្រិមប្រិយ! មានសុខភាពល្អហើយ ប៉ុន្តែឯផ្លូវចិត្តរបស់គេបែរជាកើតទុក្ខទៅវិញ, បើដូច្នោះឃើញថា គេនោះទោះបីមានរូបស្អាតក៏ដោយក៏ផ្លូវចិត្តរបស់គេមិនមានសេចក្ដីសុខនិងមិនមានសុភ-មង្គលឡើយ។ នេះជាការបញ្ជាក់ឲ្យកាន់តែឃើញច្បាស់ថារោគឬជម្ងឺតាមផ្លូវចិត្តធំធេងពន់ពេកណាស់ខ្លាំងក្លាណាស់! ប៉ុន្តែជាទូទៅមនុស្សនៅលើពិភពលោកនេះទាំងមូល ភាគច្រើនណាស់ ដែលគេចាប់អារម្ម-ណ៍ខ្លាំងតែជម្ងឺតាមផ្លូវកាយច្រើនជាងជម្ងឺតាមផ្លូវចិត្ត ឯជម្ងឺតាមផ្លូវចិត្តហាក់ដូចជាគេមិនសូវចាប់អារម្មណ៍ ដើម្បីព្យាបាលឲ្យបានជាទេព្រោះវាហាក់ដូចជាស្ថិតនៅជាអាថ៌កំបាំងពេក!។ ខ្ញុំលើកឧទាហរណ៍ពីជម្ងឺផ្លូវកាយមកបញ្ជាក់ឲ្យងាយយល់បន្តិចថាប្រសិនបើយើងណាម្នាក់មានវត្ថុអ្វីមកប៉ះពារដៃជើងខ្លួនប្រាណរបស់យើងឲ្យមានរបួស ចេញឈាមជាដើម,នោះយើងមុខជាស្ទុះស្ទាររកប្រេងកូឡាឬប្រេងខ្យល់មកលាបព្យាបាលភ្លាមៗហើយ, បើមុតខ្លាំងអាចលាងដោយអាល់កុលរួចរោយម្សៅផ្សះរុំសំឡី,រុំបង់ទៀតផងជម្ងឺផ្លូវកាយអញ្ចឹង,គេប្រញាប់ប្រញាល់អញ្ចឹងឯជម្ងឺតាមផ្លូវចិត្តវិញមិនដូច្នោះទេ គេដូចជាពិបាកមើលឃើញណាស់,ព្រោះចិត្តជាសភាវៈមិនមានរូបមិនអាចឲ្យយើងមើលឃើញដោយភ្នែកបានឡើយវាជានាមធម៌ល្អិតសុខុមណាស់ មានតែឈ្មោះសម្រាប់ហៅប៉ុណ្ណោះ។ប៉ុន្តែវាមានការពិតរបស់វា អាចឲ្យយើងកំណត់សំគាល់បាន

ដែរ!គឺចិត្តវាជាធម្មជាតចេះនឹកចេះគិតរាវ ទៅរកអារម្មណ៍ផ្សេងៗចេះរីករាយចេះទោមនស្សតូចចិត្តចេះកើតទុក្ខចេះទទួលអារម្មណ៍ជាសុខជាទុក្ខជាដើមបានដែរ។ បើតាមផ្លូវព្រះធម៌រូបនិងចិត្តនេះលោកពោលថាវាកើតរលត់ៗគ្រប់ខណៈដែល ហៅថា ខណិកមរណៈ ការស្លាប់ជាខណៈៗ នេះឯងដែលសំគាល់ថាជា“ទុក្ខ” ការទ្រាំនៅក្នុងសភាពដ៏លំបាកគឺវាចេះតែប្រែប្រួលទៅៗជាដរាប មិនឈប់។ ទុក្ខៈៗ នេះប្រែថាសភាវៈទំពារស៊ីនូវសេចក្តីសុខ។ប៉ុន្តែណ្ហើយ!សភាវៈជាបរមត្ថធម៌ទុកជូនលោកអ្នកស្រាវជ្រាវផ្នែកខាងអភិធម្មចុះ។ តទៅនេះយើងនិយាយអំពីធម៌រាក់ៗងាយៗទៅវិញចុះ ដើម្បីឲ្យវាស្រួលយល់ស្រួលស្តាប់ថាៈ មនុស្សដែលមានទុក្ខដោយជម្ងឺតាមផ្លូវកាយនិងផ្លូវចិត្តនោះបើតាមផ្លូវព្រះធម៌លោកពោលថា“ សេចក្តីទុក្ខកើតមានព្រោះសេចក្តីស្រឡាញ់ហើយសេចក្តីទុក្ខក៏កើតមានព្រោះសេចក្តីស្អប់ដែរ”ជាឧទាហរណ៍ថាៈ សេចក្តីទុក្ខកើត ព្រោះសេចក្តីស្រឡាញ់នោះ  ដូចជានរណាម្នាក់ ត្រូវព្រាត់ប្រាស់ឪពុកម្តាយ, ឬឪពុកម្តាយត្រូវព្រាត់ប្រាស់កូន, ប្តីត្រូវព្រាត់ប្រាស់ប្រពន្ធឬប្រពន្ធត្រូវព្រាត់ប្រាស់ប្តីជាទីស្រឡាញ់ពេញចិត្តជាដើមនៃ!កត្តាទាំងអស់នេះហើយដែលជាហេតុនាំឲ្យកើតទុក្ខ,ហើយបើស្រឡាញ់ខ្លាំង,កើតទុក្ខក៏ខ្លាំង,បើស្រឡាញ់ល្មម, កើតទុក្ខក៏ល្មម, បើស្រ-ឡាញ់តិចកើតទុក្ខក៏តិចដែរ!។តែផ្ទុយទៅវិញប្រសិនបើអត់ស្រឡាញ់សោះ នោះសេចក្តីទុក្ខក៏អត់មានសោះដែរ!នែ នេះជាសេចក្តីពិត,គឺវាពិតជាអញ្ចឹង។ឯសេចក្តីទុក្ខកើតមានព្រោះសេចក្តីស្អប់នោះយ៉ាងម៉េចដែរ ?ចម្លើយៈសេចក្តីទុក្ខកើតមានព្រោះសេចក្តីស្អប់នោះគឺមនុស្សអ្នកសុចរិតស្លូតត្រង់,តើស្រឡាញ់មេចោរកំណាចកាចឃោរឃៅដែរឬទេ ? ចម្លើយៈពិតជាឆ្លើយថាទេ!ទេ!ទេ រួចបើដូច្នេះ ពិតជាស្អប់ហើយ,រួចបើស្អប់ហើយពិតជាកើតទុក្ខហើយ! ប្រសិនបើបានជួប ឬនៅជិតមេចោរនោះគឺពិតជាកើតទុក្ខអញ្ចឹង។នេះទុក្ខដែលកើតមានព្រោះសេចក្តីស្អប់

ឥឡូវយើងយករឿងទាំង២នេះ មកពិចារណាដោយសុភវិនិច្ឆ័យ ទៅមើលថាៈការព្រាត់ប្រាស់គ្នាកើតទុក្ខព្រោះសេចក្តីស្រឡាញ់,ការជួបឬនៅជិតមេចោរកំណាចក៏កើតទុក្ខព្រោះសេចក្តីស្អប់,រួចយើងពិចារណាតទៅទៀតថាៈករណីទាំង២បែបនេះតើវាមានមកប៉ះពាល់ឲ្យខូចខាតឬក៏របួសស្នាមដល់រូបកាយរបស់យើងដែរឬទេ,ថាអត់ទេអត់ទេ,ដូច្នេះសេចក្តីទុក្ខវាស្ថិតនៅមុតជាប់ក្នុងសន្តានចិត្តរបស់យើងឯណោះ,បានន័យថាមនុស្សមានទុក្ខឬជម្ងឺក្នុងផ្លូវចិត្តហើយ! ។ រីឯដំណោះស្រាយជម្ងឺក្នុងផ្លូវចិត្តមានតែព្រះធម៌ទេ,មានតែព្រះធម៌មួយមុខគត់!ទើបអាចដោះស្រាយនូវរាល់បញ្ហាគ្រប់យ៉ាង ក្នុងផ្លូវចិត្តបានជាស្ថាពរនោះ! ខ្ញុំសូមលើកឧទាហរណ៍មកបញ្ជាក់ជូនៈមនុស្សដែលមានជម្ងឺក្នុងផ្លូវចិត្តខ្លាំងពេកទៅ រហូតដល់វង្វេងស្មារតីគឺរឿង“នាងកីសាគោតមី” ។ ក្នុងគម្ពីរធម្មបទបានដំណាលថាៈ នាងកីសាគោតមីនេះ មានកូនប្រុសតែម្នាក់គត់ជាទីស្រឡាញ់ណាស់! រួចកូននោះមានជម្ងឺព្យាបាលមិនជាក៏បានស្លាប់ទៅ,នាងកើតទុក្ខខ្លាំងណាស់រហូតដល់វង្វេងវង្វាន់ភ្លេចភ្លាំងសតិស្មារតីនាងបានបីសពកូនដែលស្លាប់នោះថាស្វែងរកគ្រូណាដែលពូកែសក្តិសិទ្ធ, ដើម្បីធ្វើកូនរបស់នាងឲ្យបានរស់ឡើងវិញ! នាងវង្វេងស្មារតីដល់ថ្នាក់ហ្នឹង!។លុះនាងបានទៅជួបនឹងព្រះពុទ្ធព្រះអង្គត្រាស់ថា“ម្នាលនាងគោតមីតថាគតចេះប្រោះកូនរបស់នាងឲ្យរស់ឡើងវិញបានប៉ុន្តែចូរនាងទៅរកគ្រាប់ស្ពៃ ពីគ្រួសារណាដែល មិនមានមនុស្សស្លាប់យកមកធ្វើជាថ្នាំព្យាបាល ទើបកូនរបស់នាងរស់ឡើងវិញ!នាងឮដូច្នោះត្រេកអរណាស់! ក៏ទៅស្វែងរកគ្រប់ភូមិស្រុកជាច្រើន តែមិនបានសោះ, លុះដល់ត្រឡប់មកវិញក៏ចូលទៅក្រាបបង្គំទូលព្រះពុទ្ធថាបពិត្រព្រះអង្គដ៏ចំរើន!នាងខ្ញុំម្ចាស់បានស្វែងរកគ្រប់កន្លែងអស់ហើយតែរកពុំបានទេ ពីព្រោះគ្រប់គ្រួសារសុទ្ធតែមានមនុស្សស្លាប់ទាំងអស់នេះជាឱកាសល្អទើបព្រះពុទ្ធត្រាស់ថា“ម្នាលនាងគោតមី! ឥឡូវនាង

បានដើរពិសោធដោយខ្លួននាងផ្ទាល់ស្រាប់ហើយ! ឃើញថាមនុស្ស! កើតមកហើយនៅលើដុំពិភពលោកទាំងមូលនេះ សុទ្ធតែមានសេចក្ដីស្លាប់គ្រប់ៗគ្នាដូចគ្នាទាំងអស់ដូច្នេះឯង!ចំណែកឯកូនរបស់នាងក៏នៅក្នុងចំណោមនោះដែរ។ ដូច្នេះចូរនាងដកចិត្តចេញពីកូនរបស់នាងទៅហើយចូរនាងលះបង់សេចក្ដីទុក្ខសោកស្រណោះអាឡោះអាល័យទាំងប៉ុន្មាននោះចោលឲ្យអស់ទៅ រួចចូរនាងមានស្មារតីឲ្យស្រួលល្អប្រសើរឡើងវិញហើយពិចារណានូវរូបកាយរបស់នាងផ្ទាល់ឯណោះវិញថាៈរូបកាយរបស់នាងនេះក៏ដូច្នោះដែរ, គឺនៅថ្ងៃណាមួយខ្លួននាងក៏ត្រូវស្លាប់ដូច្នោះដែរចៀសមិនផុតទេ!បើដូច្នេះនាងត្រូវស្វែងរកទីពឹងសម្រាប់ខ្លួនរបស់នាងផ្ទាល់វិញទើបប្រសើរ!។ រួចទីពឹងដ៏ប្រសើរបំផុតនោះមានតែព្រះធម៌ទេ។ នាងក៏ស្ថិតនៅស្ងៀម!ចាំស្ដាប់ព្រះពុទ្ធ!បន្ទាប់មកព្រះពុទ្ធទ្រង់ទេសនាពន្យល់នាងជាអនេកបរិយាយ!, ដោយសារព្រះធម្មរសគឺរសព្រះធម៌ទេសនារបស់ព្រះពុទ្ធ ធ្វើឲ្យនាងមានស្មារតីល្អប្រសើរឡើងវិញបាន!ដោយនាងបានពិចារណាតាមផ្លូវព្រះធម៌ ជាសេចក្ដីបំភ្លឺរបស់ព្រះពុទ្ធដ៏ល្អប្រសើរថ្លៃថ្លា នាងក៏បានលះបង់នូវសេចក្ដីទុក្ខ ទាំងអស់! ដែលបានញាំញីនាងក្នុងផ្លូវចិត្តបានយ៉ាងជ្រះស្រឡះក្នុងពេលនោះឯង គុណព្រះធម៌ដែលនាងបានស្ដាប់អំពីព្រះឱស្ឋរបស់ព្រះពុទ្ធដោយផ្ទាល់វាពូកែសក្ដិសិទ្ធិយ៉ាងហ្នឹង!គឺបញ្ហាដែលមាននៅក្នុងចិត្តរបស់នាងទាំងប៉ុន្មានត្រូវបានដោះស្រាយបញ្ចប់ជាស្ថាពរដោយព្រះធម៌យ៉ាងនេះឯង, រឿងមួយទៀតមានអ្នកមានជម្ងឺផ្លូវចិត្តដូចគ្នាមានសេចក្ដីទុក្ខសោកដូចគ្នាវង្វេងស្មារតីប្រហាក់ប្រហែលគ្នាដែរ,សេចក្ដីដំណាលថាៈមានសេដ្ឋីម្នាក់មានកូនប្រុសតែម្នាក់គត់ ហើយជាទីស្រឡាញ់ពេញចិត្តក្រៃលែងណាស់!កូននោះក៏មានជម្ងឺព្យាបាលមិនសមប្រកបក៏បានស្លាប់ទៅដែរ រួចគេទាំងឡាយបានយកសពកូននោះទៅកប់បញ្ចុះធ្វើជាផ្នូរនៅកន្លែងមួយដ៏សមគួរ។ឯសេដ្ឋីនោះដោយគាត់ស្រណោះអាឡោះអាល័យកូន

របស់គាត់ខ្លាំងពេក! ក៏ទៅយំសោកដេកឱបផ្នូរកូននោះ,យំសោកឥតឈប់, គេទាំងឡាយឃើញដូច្នោះមិនដឹងជាគិតធ្វើយ៉ាងម៉េចដើម្បីឲ្យលោកសេដ្ឋីឈប់យំសោកដេកឱបផ្នូរកូននោះទៅ,ស្រាប់តែពេលនោះមានយុវបណ្ឌិតម្នាក់ ជាអ្នកមានប្រាជ្ញាឆ្លាតប្រតិពលអាចដោះស្រាយបញ្ហានោះបាន,ក៏បានក្លែងខ្លួនធ្វើជាអ្នកមានទុក្ខដែរ,បានទៅអង្គុយយំនៅជិតសេដ្ឋីនោះ ហើយយំខ្លាំងជាងសេដ្ឋីនោះទៅទៀត,សេដ្ឋីឃើញដូច្នោះក៏សួរទៅយុវជននោះថាៈនែ!យុវជនដ៏ក្មេងស្អាត!ចុះអ្នកឯងយំហ្នឹងតើយំកើតទុក្ខពីរឿងអ្វីដែរ?យុវបណ្ឌិតឆ្លើយថា,ឱ!លោកសេដ្ឋី!ខ្ញុំយំដោយខ្ញុំចង់បានព្រះអាទិត្យ,ព្រះចន្ទ័យកមកលេងព្រោះព្រះអាទិត្យព្រះចន្ទ័នេះ  ខ្ញុំស្រឡាញ់ណាស់, ប្រសិនបើខ្ញុំមិនបានព្រះអាទិត្យ ព្រះចន្ទ័មកលេងទេ ខ្ញុំយំមិនឈប់ទេ!។ សេដ្ឋីឮដូច្នោះ ក៏អស់សំណើចរួចសើចយ៉ាងខ្លាំង,សើចហើយសើចទៀតក៏ពោលទៅរកយុវជននោះថាៈ“ នែយុវជនដ៏ល្ងង់ខ្លៅ!យុវជនឯងឆ្កួតហើយហ្នឹង! យុវជនឯង យំចង់បានទាល់តែស្លាប់ខ្លួនក៏មិនបានព្រះអាទិត្យនិងព្រះចន្ទ័មកលេងដែរ!” នែ!នេះជាឱកាសល្អដល់យុវបណ្ឌិតហើយ,យុវបណ្ឌិតបានឱកាសល្អដូច្នេះហើយក៏សួរទៅសេដ្ឋីនោះថាៈ“ឱ!លោកសេដ្ឋីយើងទាំងពីរនាក់តើអ្នកណាល្ងង់ជាងអ្នកណា?ហើយអ្នកណាឆ្កួតជាងអ្នកណា? ខ្ញុំយំចង់បានព្រះអាទិត្យ និងព្រះចន្ទ័ ជារបស់ ដែលយើងមើលឃើញទាំងអស់គ្នា ចំណែកឯលោកសេដ្ឋីវិញយំទួញសោកពីរឿងកូនរបស់លោកដែលស្លាប់,ហើយគេបានកប់បាត់ទៅក្នុងដីទៅហើយនោះ!តើកូននោះវាអាចរស់ឡើងវិញបានដែរឬទេ?សេដ្ឋីឮដូច្នោះក៏ភ្ញាក់ខ្លួនព្រើត!ដូចជារបូតជ្រុះសេចក្តីសោកសៅ ស្រណោះអាឡោះអាល័យ អស់ពីខ្លួនរលីង!ដោយពិចារណាឃើញថា “ ឱ!ខ្លួនឯងនេះ វាល្ងង់ជាងយុវជននោះណាស់ទៅទៀត,ក៏ឈប់យំហើយក្រោកក្រេះដើរចេញពីផ្នូរយ៉ាងប្រញាប់ដោយសេចក្តីអៀនខ្មាសយ៉ាងខ្លាំងព្រោះខ្លួនឯងបានសើចចំ-

អកឲ្យគេនិងដៀលគេជ្រុលហួសទៅទៀត, រួចបែរជារឿងនេះវាប៉ះមកលើខ្លួនឯងឯណោះវិញសោះ។ខ្ញុំលើករឿងទាំងពីរនេះមកដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថាមនុស្សដែលមានវិបត្តិផ្លូវចិត្តមានតែព្រះធម៌ទេទើបដោះស្រាយបាន, គឺប្រសិនបើដោះស្រាយឲ្យចំចំណុចរបស់វា, វាជ្រះស្រឡះបានភ្លាមមួយរំពេចអញ្ចឹង!ដូចសេដ្ឋីនេះឈប់យំហើយក្រោកក្រេសដើរចេញដោយឥតបែរក្រោយឡើយ!។ នែ! ឯដំណោះស្រាយតាមផ្លូវព្រះធម៌វាពូកែសក្តិសិទ្ធិអញ្ចឹង។ប៉ុន្តែជម្ងឺផ្លូវចិត្តនេះមានមនុស្សមួយចំនួនខ្លះ គេបានប្រថុយដោះស្រាយតាមផ្លូវ អបិយ ជំនឿផងដែរ! ដូចជាដំណោះស្រាយខ្លះដែលមនុស្សខ្លះគេធ្លាប់បានសាកល្បងដោះស្រាយរួចមកហើយ,គឺមនុស្សខ្លះកាលណាគេមានវិបត្តិផ្លូវចិត្តគេបានលេបថ្នាំឲ្យដេកលក់,ឬផឹកឬជក់គ្រឿងស្រវឹងគ្រឿងញៀនអ្វីផ្សេងៗថាដើម្បីបំបាត់ទុក្ខឬបំភ្លេចទុក្ខ,ប៉ុន្តែអំពើបែបនេះឬដំណោះស្រាយរបៀបនេះមិនអាចបំបាត់ទុក្ខបានឡើយ កាលណាភ្ញាក់ឡើងសេចក្តីទុក្ខនៅតែដដែល! ថែមទាំងជួនកាលវាបណ្តាលឲ្យខូចសុខភាពផងក៏មាន។ មានអ្នកខ្លះកើតទុក្ខខ្លាំងពេកទៅៗជារកចងកឬរករត់ចូលផ្លូវរទេះភ្លើងឬលោតចូលភ្លើង, លោតចូលទឹក,ជាដើម, ថាសម្លាប់ខ្លួនដើម្បីបំបាត់ទុក្ខប៉ុន្តែដំណោះស្រាយបែបនេះរឹតតែមិនអាចបំបាត់សេចក្តីទុក្ខបានទៅទៀតហើយ! គឺអ្នកស្លាប់នោះស្លាប់ទាំងបន្តទុក្ខទៅជាតិមុខទៀត, ព្រោះជាតិបច្ចុប្បន្ននេះ ហេតុដែលនាំឲ្យកើតទុក្ខនោះគេមិនបានដោះស្រាយនៅឡើយ, ម្លេ៉ះហើយវានឹងបណ្តាលឲ្យមានអនាគតផលទៅជាតិមុខទៀតជាប្រាកដ!គឺបញ្ហាវាត្រូវស្ថិតនៅដឹតជាប់ក្នុងចិត្តតាមទៅជាមួយដែរ ឯការស្លាប់វាគ្រាន់តែឃ្លាតចេញពីបញ្ហាមួយរយៈពេល ឬមួយគ្រាតែប៉ុណ្ណោះ!។ មនុស្សខ្លះមានសេចក្តីទុក្ខក្នុងផ្លូវចិត្ត គេនាំគ្នាទៅបន់ស្រន់ទេវតា,ឥន្ទ,ព្រហ្ម ឬបន់ព្រះសុំឲ្យព្រះជួយខ្លួនឲ្យបាត់ទុក្ខ, មានអ្នកខ្លះទៀតទៅរកគ្រូទស្សន៍ទាយ, សេកមន្តអាគមគាថា,កន្សែង

យ័ន្ត ថាដើម្បីឲ្យជួយរំដោះទុក្ខឲ្យខ្លួនបានជាសះស្បើយពីទុក្ខ!។ ប៉ុន្តែដំណោះស្រាយបែបនេះវាគ្រាន់តែបានជួយលើកកម្លាំងទឹកចិត្តបានខ្លះដែរ,ប៉ុន្តែមិនអាចបំបាត់សេចក្តីទុក្ខឲ្យជ្រះស្រឡះទាំងស្រុងបានឡើយ ព្រោះបញ្ហាដែលមាននៅក្នុងចិត្ត គេមិនបានដោះស្រាយ។ សេចក្តីថា: ការកើតទុក្ខក្នុងផ្លូវចិត្តមកពីមានហេតុដែលនាំឲ្យកើតទុក្ខ, រួចបើគេមិនបានដោះស្រាយឬរំលត់ហេតុនោះឲ្យរលត់ទេ នោះសេចក្តីទុក្ខក៏នៅតែមានដដែល។ ដូច្នេះបានជាថាសេចក្តីទុក្ខក្នុងផ្លូវចិត្តមានតែព្រះធម៌ទេ ទើបអាចដោះស្រាយឲ្យជ្រះស្រឡះបានជាស្ថាពរនោះ!។ មានមនុស្សខ្លះទៀត កើតទុក្ខពីរឿងអ្វីមួយមិនព្រមដោះស្រាយ ទៅតាមហេតុតាមបច្ច័យរបស់វាទេបែរជាទៅបន្ទោសព្រហ្មលិខិតឯណាឯណោះ ទៅវិញឆ្កុយ ដូចមានមនុស្សខ្លះបានគ្នាជាប្តីប្រពន្ធហើយ តែមិនយូរប៉ុន្មានផងក៏បែកគ្នាទៅវិញ, រួចក៏មិនព្រមនាំគ្នាដោះស្រាយទៅតាមហេតុ-បច្ច័យនៃបញ្ហាទេ! បែរជានិយាយថា"ហ៊ឺះ!ធ្វើម៉េចហ្ន៎!បើព្រហ្មលិខិតចារមកឲ្យបានជួបគ្នាតែប៉ុណ្ណឹង!នែទៅជាមានគំនិតជឿបែបនេះទៅវិញក៏មានមានរឿងខ្លះទៀត ដូចជាមានយុវជនយុវតីខ្លះ មានវិបត្តិខាងផ្លូវស្នេហាខ្លាំងពេកដោះស្រាយមិនរួច, រួចមិនព្រមបន្ទោសខ្លួនឯងដែលនាំគ្នាដើរផ្លូវខុសទេ! បែរជាទៅបន្ទោសព្រហ្មលិខិតឯណាឯណោះឆ្កុយទៅវិញ! អញ្ចឹង!ក៏មាន។ សាធុសប្បុរសទាំងឡាយ!សូមយល់ឲ្យច្បាស់ថា: គំនិតដែលជឿព្រហ្មលិខិតបែបនេះ ជាជំនឿតាមបែបព្រហ្មញ្ញសាសនាទេ ដែលគេជឿថាគឺព្រះព្រហ្មជាអ្នកឲ្យសុខឲ្យទុក្ខ ដល់មនុស្សលោកនោះ,មិនមែនជាជំនឿផ្នែកខាងព្រះពុទ្ធសាសនាទេ។ឯជំនឿផ្នែកខាងព្រះពុទ្ធសាសនា គឺជឿលើកម្មនិងផលរបស់កម្ម, បានន័យថាមនុស្សសត្វទូទៅនៅលើពិភពលោកនេះទាំងមូល បានសេចក្តីសុខ-ទុក្ខ ឬចំរើនវិនាសយ៉ាងណានោះ! អាស្រ័យមកពីអំពើកម្មដែលខ្លួនឯងម្នាក់ៗបានកសាងល្អឬអាក្រក់របស់ខ្លួនដោយផ្ទាល់ខ្លួនរៀងៗខ្លួនទាំងអស់!

មិនមែនព្រះព្រហ្មលិខិត, ឬព្រះអាទិទេពណានោះជប!ឲ្យនោះឡើយ! (ឥសីជប,អត់បន្តក់ ទេ។ ដូច្នេះអ្នកកាន់ព្រះពុទ្ធសាសនាទាំងឡាយ សុំកុំឲ្យមានជំនឿភន្ត័ច្រឡំប្រាសចាកពីការពិតឲ្យសោះ! កុំយល់ខុសឲ្យសោះ ព្រោះថា ប្រសិនបើមនុស្សណាមួយយល់ខុសហើយ គិតអ្វីក៏ខុស, និង និយាយអ្វីក៏ខុសធ្វើអ្វីក៏ខុសហើយបានផលមកវិញក៏ខុស,រួចផលដែលខុសនោះ វាច្រើនតែជាទុក្ខ,ទុក្ខលំបាកណាស់!នេះជាសេចក្តីពិតដែលពិតស្របទៅតាមកម្មផល,តាមហេតុបច្ច័យដែលមនុស្សម្នាក់ៗបាន ក-សាងដោយខ្លួនឯងផ្ទាល់,មិនមាននរណាកសាងជំនួសឲ្យនរណាម្នាក់ទៀតបានទេ!ប្រៀបជាឧទាហរណ៍ថាៈប្តី-ប្រពន្ធពីរនាក់អង្គុយទល់មុខគ្នានៅតុបាយមួយជាមួយគ្នាដែលមានបាយ១ចាន,ម្ហូប១ចាន, គឺបើប្តីបរិភោគប្តីនឹងឆ្អែត,បើប្រពន្ធបរិភោគប្រពន្ធនឹងឆ្អែត,រួចបើប្តីនិងប្រពន្ធបរិភោគទាំង២នាក់នឹងឆ្អែតទាំងអស់គ្នា,មិនអាចប្តីបរិភោគតែម្នាក់ឯងហើយឲ្យឆ្អែតដល់ប្រពន្ធផងបានទេ!,នេះជារឿងពិត!ជាសច្ចៈធម៌!។ បានន័យថា ទង្វើអ្វីក៏ដោយមិនអាចនរណាម្នាក់ ធ្វើជំនួសនរណាម្នាក់ទៀតបានទេ, ឯលទ្ធផល ក៏មិនអាចនរណា ទទួលជំនួសនរណាម្នាក់ទៀតបានដែរ!។ នេះជាសច្ចៈធម៌វាមានសច្ចភាពណាស់!។ អាស្រ័យហេតុនេះ ជាមនុស្ស! នៅលើដុំពិភពលោកនេះទាំងមូល ទាំងអស់គ្នា ប្រសិនបើមានបញ្ហាអ្វីកើតឡើងទោះតូចក្តីធំក្តី ត្រូវនាំគ្នាប្រញាប់ដោះស្រាយទៅតាមហេតុផលរបស់វា!កុំទុកយូរព្រោះថាប្រសិនបើទុកយូរទៅ បញ្ហានោះវាកាន់តែរីកថ្លោសធំឡើងៗ ច្រើនឡើងៗកាន់តែតានតឹងឡើងៗនាំឲ្យពិបាកដោះស្រាយ នៅពេលក្រោយ ។ រួចប្រសិនបើដោះស្រាយដោយខ្លួនឯងមិនរួចទេ,សូមរកលោកអ្នកសប្បុរសអ្នកចេះដឹងធម៌អាចំឲ្យជួយដោះស្រាយ,ព្រោះថារាល់បញ្ហាអ្វីក៏ដោយមានតែព្រះធម៌ទេទើបអាចដោះស្រាយឲ្យជ្រះស្រឡះជាស្ថាពរបាន។ នៅក្នុងរូបកាយនេះដដែលមានមនុស្សខ្លះបែរជាខំប្រមូលបញ្ហាមកទុកក្នុងខ្លួន

ដោយមិនដឹងខ្លួន, គឺរឿងរបស់អ្នកដទៃសោះទេ តែក៏ប្រមូលយកមក ទុកនៅក្នុងចិត្តរបស់ខ្លួន!។ ខ្ញុំលើកឧទាហរណ៍ជាសេចក្ដីឧបមា ថាៈ មានឧបាសកម្នាក់ឈ្មោះ “ក”,ឧបាសិកាម្នាក់ឈ្មោះ“គ”,និងយុវជន ម្នាក់ឈ្មោះ“ង”ជាយុវជនខឹលបន្តិច។នៅថ្ងៃមួយយុវជនបានជួបនិង ឧបាសិកា“គ”កំពុងយួរចានស្រាក់ទៅវត្ត យុវជនលើកដៃសំពះជំរាប សួរថា“ លោកយាយអញ្ជើញទៅវត្តឬ? យាយឆ្លើយ“ អឺចៅ! យាយ ទៅវត្ត” យុវជនថា“ ចុះថ្ងៃសីលអញ្ចឹងមានមនុស្សទៅច្រើនទេលោក យាយ?”យាយថា“មាន១០ឬ២០នាក់ដែរណាចៅ”។ យុវជនលើក ដៃសំពះម្ដងទៀតហើយនិយាយថាៈសូមអភ័យទោសលោកយាយ,ខ្ញុំ បាទសូមជំរាបលោកយាយរឿងមួយ តែសូមលោកយាយកុំខឹងហ្នាំ! យាយថាៈមានអីចៅនិយាយទៅយាយមិនខឹងនឹងចៅទេ!យុវជនបន្ត ថាៈកាលពីថ្ងៃមុនលោកតា“ក”បាននិយាយថា“លោកយាយអញ្ជើញ ទៅវត្តនិយាយតែពីរឿងគេទេ មិនដែលនិយាយពីធម៌អាថ៌អ្វីទេ រួចថា លោកយាយ! បើមានអ្នកណានិយាយ ឲ្យទាស់ចិត្តតែបន្តិច, លោក យាយជេរគេ, ជេរឯងឥតប្រណីទេ!” ។ យាយ“គ”ឆ្លើយថា“យី! តា “ក”និយាយអញ្ចឹងមែនឬ? យុវជនតបថា“សូមលោកយាយកុំខឹងអី ខ្ញុំបាទអាណិតលោកយាយទេបានជាជំរាបនេះ! ណ្ហើយ! កុំឲ្យខាត ពេលលោកយាយខ្ញុំបាទសូមជំរាបលាសិនហើយ!។ ក៏ឯយាយ“គ” កាលបានឮពាក្យដូច្នោះហើយ មិនបានជាពិចារណាអ្វីទេ ក៏មួម៉ៅក្នុង ចិត្តខ្លាំងណាស់គិតថាៈមិនគួរបើតា“ក”និយាយបង្ខូចកេរ្តិ៍ដូច្នេះសោះ ហើយគិតថាៈបើបានជួបតា“ក”ពេលណា?នឹងសួរឲ្យដឹងសដឹងខ្មៅ ហើយនឹងស្ដីថាឲ្យតាហ្នឹងឲ្យណាណីម្ដង!ហើយក៏ចេះតែគុំទុកកំហឹង ក្នុងចិត្តមមែ!ជារហូតអស់រយៈពេលច្រើនថ្ងៃច្រើនយប់អញ្ចឹងទៅ!។ រឿងបែបនេះហើយ ដែលហៅថារឿងរបស់គេសោះ ហើយយកមក ទុកនៅក្នុងចិត្តរបស់ខ្លួននោះ!គឺរឿងតា“ក”ឯណោះសោះ,ហើយតា

“ក”នោះក៏ឥតបានដឹងខ្លួនផងទៀតរួចយកមកខឹងទុកតែក្នុងចិត្តរបស់ខ្លួនឯង(មកពីមិនទាន់ជឿខ្លួនឯង); ប្រសិនបើតាកនិយាយដូច្នេះមែនទៅចុះ,នោះផលជាបាប វានៅលើតាក ជាអ្នកទទួលទេតើ! យើងទៅកើតទុក្ខធ្វើអី?យកមកធ្វើទុកក្នុងចិត្តរបស់ខ្លួនធ្វើអី?។ នេះឯងហើយដែលហៅថារឿងរបស់អ្នកដទៃសោះ រួចយកមកធ្វើទុកក្នុងចិត្តរបស់ខ្លួនឲ្យតែអំពល់នោះ!។រឿងប្រឌិតរបៀបនេះក៏បានជាគតិគួរឲ្យយើងទុកគ្រាន់ពិចារណាតទៅដែរ!។ ហៃសាធុ!សប្បុរសទាំងឡាយ!តទៅយើងត្រូវពិចារណាអំពី រូបកាយរបស់យើងទាំងអស់គ្នាផ្ទាល់តែម្តងគឺយើងត្រូវពិចារណាទៅតាមសកម្មភាពដ៏ល្អប្រសើរ របស់ចាស់ទុំបុរមបុរាណ,ជីដូនជីតារបស់យើងថា,កាលលោកនៅពីក្មេងដែលជាប់រវល់តែពីរឿងរកទ្រព្យសម្បត្តិ ដើម្បីផ្គត់ផ្គង់ដល់ជីវភាពគ្រួសារម្ល៉ោះហើយលោកមិនបានជាចាប់អារម្មណ៍ពីអំរឿងធ្វើទាន-រក្សាសីលចំរើនមេត្តាភាវនាអ្វីប៉ុន្មានទេ!លុះតែដល់ពេលដែលលោកមានវ័យចំណាស់ពាក់កណ្តាលអាយុមនុស្សហើយទើបលោកសម្រាក,លោកបន្ធូរដៃក្នុងការស្វែងរកទ្រព្យសម្បត្តិខ្លះហើយ, លោកបែរមកព្យាយាមធ្វើទាន, សីល, សមាទានសីល,ចំរើនមេត្តាភាវនាជាញឹកញាប់វិញហើយដោយលោកយល់ឃើញថា,ជីវិតនៅវ័យចុងក្រោយរបស់មនុស្សលោកនៅលើពិភពលោកទាំងមូលនេះជារឿងសំខាន់ណាស់ពិតមែនតែជីវិតរបស់មនុស្សគ្រប់រូបមិនទៀងទាត់, មិនដឹងជាត្រូវស្លាប់នៅពេលណា?ថ្ងៃណា?ខែណា?ឆ្នាំណា?ម៉ោងណា?ប៉ុន្តែដល់វ័យចាស់ហើយ! យើងទាំងអស់គ្នាក៏អាចសន្និដ្ឋានបានហើយថា:វានឹងជិតដល់ពេល“មរណៈ”ហើយ! ម្ល៉ោះហើយលោកតែងស្វែងរកទីពឹងគឺទៅថ្វាយខ្លួនដល់ព្រះរតនត្រ័យខំធ្វើទាន,រក្សាសីលចំរើនមេត្តាភាវនា,ធ្វើចិត្តឲ្យស្អាត!មានយកចង្ហាន់ទៅប្រគេនព្រះភិក្ខុសង្ឃរាល់ថ្ងៃសីលជាដើម! ឲ្យបានញឹកញាប់និងធ្វើបុណ្យកុសលផ្សេងៗទៀត!, មានការជួយសង្គ្រោះជនអ្នកក្រីក្រកំសត់

ទុគ៌ត,ជរា,ពិការ,អ្វីផ្សេងៗជាដើម,និយាយឲ្យខ្ពស់ជាងនេះ,ដល់លោក
អ្នកមានគុណទាំងឡាយមានមាតាបិតាជាដើម,ទុកជាទុនជាស្បៀងសំ
រាប់អនាគតជាតិឲ្យហើយមុននឹងស្លាប់ព្រោះអំពើទាំងនេះជាទីពឹងពាក់
ដ៏សំខាន់បំផុតសំរាប់ជីវិតទៅជាតិខាងមុខ។ ការធ្វើយ៉ាងនេះ គឺលោក
ធ្វើសម្រាប់ជីវិតចុងក្រោយរបស់ខ្លួនម្នាក់ៗព្រោះថាៈបុណ្យកុសលនេះ
សំខាន់ណាស់!សម្រាប់“ដង្ហើម”ចុងក្រោយរបស់មនុស្សគ្រប់ៗរូប! ។
ដែលហៅថា“ដង្ហើម”ចុងក្រោយនោះគឺមនុស្សម្នាក់ៗ ពេលដែលជិត
ដាច់ខ្យល់ស្លាប់,គឺដង្ហើមចេញពី“ស្សួត”មកអស់ហើយនៅត្រឹមតែបំពង់
“ក”និងចុងច្រមុះតែប៉ុណ្ណោះ គឺ“ផ្ដឹតផ្ដក់ៗ”, ពេលនោះភ្នែកមើលអ្នក
ណាក៏លែងឃើញហើយ, ត្រចៀកស្ដាប់នរណាលែងឮហើយ, ទោះបី
នរណាឲ្យធម៌“ពុទ្ធោ”យ៉ាងម៉េចក៏ដោយក៏មិនឮដែរ!គឺពេលហ្នុង!មាន
តែម្នាក់ឯងគត់ “ដង្ហើមផ្ដឹតផ្ដក់ៗ” តែងឃើញតែម្នាក់ឯងគត់ក្នុងចិត្តនូវ
“អារម្មណ៍”៣យ៉ាងណាមួយគឺ១-កម្មារម្មណ៍អារម្មណ៍ឃើញអំពើដែល
ខ្លួនកំពុងធ្វើ“ជាបុណ្យឬជាបាប”។ ២-កម្មនិមិត្តារម្មណ៍អារម្មណ៍និមិត្ត
ឃើញអំពើដែលខ្លួនបានធ្វើរួចហើយ!។ ៣-គតិនិមិត្តារម្មណ៍អារម្មណ៍
ឃើញដំណើរផលនៃកម្មដែលខ្លួនបានធ្វើហើយ!,ឲ្យឃើញដូចជាប្រា-
សាទវិមានឬវាំងហ្លួងជាដើម,នេះបើជាបុណ្យ!។ បើជាបាបវិញឃើញ
ដូចជាទ្រុង,គុក,ច្រវាក់ឬខ្នោះឃ្នាងជាដើម។ នៅពេលដែលកំពុងដក
ដង្ហើមផ្ដឹតផ្ដក់ៗហ្នុង! បើជវនចិត្តវាឃើញអារម្មណ៍ណាមួយ, ប្រសិន
បើដាច់ខ្យល់ប៉ិតស្លាប់ទៅបដិសន្ធិវិញ្ញាណវាស្ទុះរឹង!ទៅកន្លែងហ្នុងៗ
ហើយ! ចុតិចិត្តឬចុតិវិញ្ញាណ (ដាច់ខ្យល់) បានប្រគល់អារម្មណ៍ទៅឲ្យ
បដិសន្ធិចិត្តឬ បដិសន្ធិវិញ្ញាណ(ចាប់ភពថ្មី)។ បដិសន្ធិវិញ្ញាណ ទទួល
អារម្មណ៍កម្មទាំងនោះណាមួយពីចុតិចិត្តទៅបដិសន្ធិនៅភពណាមួយ
តាមអារម្មណ៍នោះៗ។សួរថាៈតាមអារម្មណ៍នោះៗយ៉ាងម៉េច?ឆ្លើយៈ
គឺបើជា“បាប”ដូចជាអារម្មណ៍ឃើញថាៈកំពុងសំឡាប់មាន់ជាដើម,រួច

កំពុងដកដង្ហើមផ្អឹតផ្អក់ៗលុះដាច់ខ្យល់ប៉ិតស្លាប់ទៅបដិសន្ធិវិញ្ញាណវា ទាញរឹងទៅក្នុងទ្រុងឬនរក ឯណោះភ្លាមមួយរំពេច!។ រួចបើជាបុណ្យ វិញដូចជាអារម្មណ៍ឃើញថា:កំពុងប្រគេនចង្ហាន់ព្រះសង្ឃ,ជាដើម.រួច កំពុងដកដង្ហើមផ្អឹតផ្អក់ៗនោះលុះដាច់ខ្យល់ស្លាប់ទៅ,បដិសន្ធិវិញ្ញាណ ទាញរឹងទៅរកវិមានប្រាសាទដ៏ប្រសើរឯនោះភ្លាម!។នេះហើយ!ដែល ហៅថាដង្ហើមចុងក្រោយ!។ ដូច្នេះយើងគ្រប់ៗគ្នាត្រូវតែប្រយត្ន័ណាស់ នៅដង្ហើមចុងក្រោយនេះ!រឿងចុតិចិត្តនិងបដិសន្ធិចិត្តប្រគល់អារម្មណ៍ ឲ្យគ្នានោះលឿនរហ័សណាស់!យើងមិនអាចមើលដឹងដោយមំសៈចក្ខុ ភ្នែកធម្មតាបានទេ! , លុះតែមើលដោយភ្នែក“បញ្ញា”ឬ(លោកុត្តរបញ្ញា) ទើបអាចដឹងបាន!ខ្ញុំប្រៀបឧបមា,ឲ្យងាយយល់ថា:ពីសហរដ្ឋអាមេរិក នេះទៅស្រុកខ្មែរយើងមានចម្ងាយរាប់ម៉ឺនគីឡូម៉ែត្រ,រួចបើយើងស្គាល់ វាំងហ្លួងនៅស្រុកខ្មែរឯណោះច្បាស់! រួចខ្លួនយើងកំពុងតែអង្គុយនៅឯ សហរដ្ឋអាមេរិកឯណោះទេ ហើយយើងគ្រាន់តែនឹកគិតទៅគឺចិត្តរបស់ យើងបានឃើញវាំងហ្លួងនៅឯស្រុកខ្មែរឯណោះ! ច្បាស់ក្រឡែតបាត់ ទៅហើយ។ គឺសន្ទុះចិត្តវាលឿនយ៉ាងហ្នឹង!ឯចុតិចិត្ត និង បដិសន្ធិចិត្ត ប្រគល់អារម្មណ៍ឲ្យគ្នាគឺវាលឿនរហ័សអញ្ចឹង។ ចំណុចត្រង់នេះលោក អ្នកសប្បុរសអាចពិចារណាយល់បានហើយថា:អ្នកខ្លះដាច់ខ្យល់ស្លាប់ នៅសហរដ្ឋអាមេរិកឯណោះទេតែអាចទៅចាប់បដិសន្ធិកើតនៅឯស្រុក ខ្មែរឯណោះបានឬក៏ដាច់ខ្យល់ស្លាប់នៅឯស្រុកខ្មែរឯណោះទេ,តែអាច មកចាប់បដិសន្ធិកើតនៅឯសហរដ្ឋអាមេរិកឯណោះភ្លាមបានដែរ,គឺ ឲ្យ តែមានហេតុមានបច្ច័យគ្រប់គ្រាន់,មានកុសលវិបាក, ជាជនកកម្មសព្វ គ្រប់,ផ្តល់ឱ្យតាមរយៈសន្ទុះចិត្តហ្នឹងឯង។ ឯល្បឿនចិត្តវាលឿនរហ័ស ណាស់នៅលើពិភពលោកនេះគ្មានអ្វីលឿនស្មើនឹងសន្ទុះចិត្តនេះឡើយ សាធុជនទាំងឡាយ! ខ្ញុំលើករឿងជាក់ស្តែងមួយមកជូនជ្រាបថាកាល ពីជំនាន់ព្រះពុទ្ធទ្រង់គង់ធរមាននៅឡើយ,ពីរឿងដង្ហើមចុងក្រោយនេះ

មកបង្ហាញជូនឲ្យឃើញជាក់ច្បាស់ក្នុងសីលកាមេ គឺរឿងនាង មល្លិកា ជាមហេសី របស់ព្រះបាទបសេនទិកោសលព្រះរាជាក្រុងសាវត្ថី,នាងបានប្រព្រឹត្តមោះ មិនគាប់ជាមួយសត្វ សុនខ ឆ្កែឈ្មោលចិញ្ចឹមដែលស្និទ្ធស្នាល។លុះដល់ព្រះរាជាទ្រង់ជ្រាបព្រះអង្គត្រាស់សួរ,ឯ មល្លិកា នាងមានល្បិចខ្ពស់ណាស់!មានបញ្ញាវៃឆ្លាតណាស់!នាងឆ្លើយកុហកបំប្លែងសេចក្តីធ្វើឲ្យទាល់តែព្រះរាជាជឿថាៈនាងឥតបានប្រព្រឹត្តមោះមិនគាប់អ្វីទេ!, តែដល់ពេលនាងជិតដាច់ខ្យល់ស្លាប់, គឺនៅដង្ហើមចុងក្រោយរបស់នាងៗមានវិប្បដិសារីស្តាយក្រោយគិតថា“ ឱ!អាត្មាអញ! មិនគួរប្រព្រឹត្តមោះមិនគប្បីហើយ,បែរជាកុហកព្រះស្វាមីអញ្ចឹងសោះ! នាងគិតដូច្នេះជាប់នឹងជវន័ចិត្តចុងក្រោយរបស់នាង,រួចដង្ហើមផ្អឹតផ្អក់ៗនាងនឹកឃើញអំពើបាបនោះលុះដាច់ខ្យល់ស្លាប់ទៅបដិសន្ធិវិញ្ញាណ ឆក់នាងរឹងទម្លាក់ទៅរងទុក្ខក្នុងនរកភ្លាម! អស់រយៈពេល៧ថ្ងៃមនុស្ស, ក្នុងគម្ពីរថាៈ៧ថ្ងៃមនុស្សប្រហែលមួយប៉ប្រិចភ្នែករបស់ទេវតាប៉ុណ្ណោះព្រោះទេវតាមានអាយុវែងណាស់។ នាង មល្លិកាជឿជាក់ពុទ្ធសាសនាមុតមាំណាស់, បានធ្វើបុណ្យច្រើនណាស់ពីមុនៗមក, ទាស់តែប្រព្រឹត្តខុសបន្តិចប៉ុណ្ណឹង!។ ដោយផលានិសង្សនៃបុណ្យដែលនាងបានសាងសន្សំពីមុនមកច្រើនក៏បានរំដោះនាងឱ្យរួចពី នរក នោះមក!, បានទៅកើតនៅក្នុងតុសិតសួគ៌ទេវលោកទៅ។ ដូច្នេះយើងត្រូវប្រយត្ន័ណាស់នៅដង្ហើមចុងក្រោយនេះ។លើករឿងនាងមល្លិកានេះមកដើម្បីបង្ហាញថានៅដង្ហើមចុងក្រោយនេះសំខាន់ណាស់!ដូច្នេះយើងគ្រប់គ្នាត្រូវខំធ្វើបុណ្យឲ្យច្រើនៗនៅអាយុចុងក្រោយរបស់យើងម្នាក់ៗនេះដើម្បីដង្ហើមចុងក្រោយឱ្យអារម្មណ៍របស់យើងវាដឹតជាប់តែនិងបុណ្យៗ! ល្អៗទៅ! លុះដង្ហើមកំពុងផ្អឹតផ្អក់ៗដាច់ខ្យល់ស្លាប់ទៅ បដិសន្ធិវិញ្ញាណ នឹងឆក់ស្ទុះរឹងទៅកាន់ស្ថានសួគ៌សុគតិភពឯណោះភ្លាមតាមអារម្មណ៍នោះៗ

ព្រះធម៌ទេសនា ស្តីអំពី“រូបកាយ”បញ្ចប់ដោយសង្ខេបប៉ុណ្ណោះហោង!